

# ពិតជាគួរឲ្យភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលឃើញច្រករបៀងវប្បធម៌កម្ពុជា-ចិន

# 看见中柬文化走廊，十分惊喜

នៅខែតុលា ឆ្នាំ២០២៣ អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរនៅកម្ពុជាបានបើកដំណើរការជាផ្លូវការ។ ផ្លូវហោះហើរកំពុងកើនឡើងឥតឈប់ឈរ ហើយចរាចរណ៍អ្នកដំណើរកំពុងកើនឡើងជាលំដាប់ ដោយភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងប្រទេសចិន និងកម្ពុជា។

នៅខែសីហា ឆ្នាំនេះ ច្រករបៀងវប្បធម៌កម្ពុជា-ចិន នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរបានបើកជាផ្លូវការ វាបានក្លាយទៅជាតំណភ្ជាប់វប្បធម៌ នាំយកជំនួបបេតិកភណ្ឌពិភពលោក ពួតដៃអរិយធម៌ក្នុងការសិក្សាពីគ្នាទៅវិញទៅមក និងកសាងស្ពានចំណងមិត្តភាព ដើម្បីបង្កើនការយល់ដឹងគ្នាទៅវិញទៅមក និងសមាហរណកម្ម។

ឆ្នាំ២០២៤ គឺជា "ឆ្នាំនៃការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន ចិន-កម្ពុជា"។ ជាមួយនឹងការកសាង សហគមន៍វាសនារួមចិន-កម្ពុជា ឈានចូលយុគសម័យថ្មីដោយ



2023 年 10 月，柬埔寨暹粒吴哥国际机场通航运营。航班航线不断增加，旅客流量稳步上升，把中国与柬埔寨紧紧联系在一起。

今年 8 月，柬埔寨暹粒吴哥国际机场中柬文化走廊启用。它成为一条文化纽带，让世界遗产面对面，文明互鉴手拉手，搭建起了友谊之桥，增进了相知相融。

2024 年是“中柬人文交流年”。随着中柬命运共同体建设进入高质量、高水平、高标准的新时代，人文交流在中柬“钻石六边”合作架构中扮演着更加重要的角色。本期，云南省南亚东南亚区域国际传播中心《高棉》杂志与您相聚在历史悠久、风光旖旎的暹粒，拥抱千年文明，同心守护世界遗产，续写友谊的故事。柬埔寨谚语说，“信任如树”。中柬友好的大树枝繁叶茂，中柬文化走廊为这棵大树继续蓬勃生长孕育新的希望。

ទេសភាពរាត្រីនៃអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរប្រទេសកម្ពុជា
夜幕下的柬埔寨暹粒吴哥国际机场 供图

គុណភាពខ្ពស់ កម្រិតខ្ពស់ និងស្តង់ដារខ្ពស់ ការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន និងវប្បធម៌ដើរតួនាទីកាន់តែសំខាន់ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ "ត្បូងពេជ្រ" រវាងប្រទេសចិន និងកម្ពុជា។ ខែនេះ ទស្សនាវដ្តី «ខ្មែរ» នៃមជ្ឈមណ្ឌលផ្សព្វផ្សាយអន្តរជាតិចំពោះតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ខេត្តយូណាន សូមនាំមកជូនលោកអ្នកនូវខេត្តសៀមរាប ដែលជាទីក្រុងមានប្រវត្តិដ៏យូរលង់ និងមានទេសភាពដ៏ស្រស់ស្អាត ដើម្បីឱបក្រសោបអរិយធម៌ពាន់ឆ្នាំ រួមការពារបេតិកភណ្ឌពិភពលោក ហើយបន្តសរសេររឿងចំណងមិត្តភាព។ សុភាសិតខ្មែរមួយឃ្លាពោលថា "ទំនុកចិត្តប្រៀបដូចជាដើមឈើ" មែកឈើធំនៃមិត្តភាពចិន-កម្ពុជាកំពុងរីកដុះដាល ហើយច្រករបៀងវប្បធម៌កម្ពុជា-ចិនបានពូនជ្រំនូវក្តីសង្ឃឹមថ្មីសម្រាប់ដើមឈើដ៏ធំមួយនេះដើម្បីបន្តលូតលាស់យ៉ាងខ្លាំងក្លា។



# រួមគ្នាអភិរក្សបេតិកភណ្ឌពិភពលោក

# 同心守护世界遗产

本刊记者 黄议娴 储东华 刘子语 / 文

今年6月，中国（云南）—柬埔寨“游云南 看吴哥”遗产地之声系列活动在昆明启动。两个月后，新老朋友相聚暹粒，以一条机场里的中柬文化走廊续写友谊的故事。通过图片展、快闪表演和传统手工艺品展示等活动，增进了两国的相互了解和友谊，为中柬“钻石六边”合作架构注入了新动力。

នៅក្នុងខែមិថុនា ឆ្នាំនេះ សកម្មភាពសំឡេងទីតាំងបេតិកភណ្ឌ "ដើរកម្សាន្តនៅយូណាន ទៅទស្សនានៅអង្គរ" នៃប្រទេសចិន(ខេត្តយូណាន)-ព្រះរាជាណាចក្រកម្ពុជាបានបើកនៅទីក្រុងគុនមីង ខេត្តយូណាន។ ពីរខែក្រោយ មិត្តចាស់និងថ្មីបានមកជួបជុំគ្នានៅខេត្តសៀមរាបនៃប្រទេសកម្ពុជា ដើម្បីបន្តសរសេររឿងចំណាងមិត្តភាពតាមរយៈច្រករបៀងវប្បធម៌កម្ពុជា-ចិនក្នុងព្រលានយន្តហោះ។



ក្នុងពិធីសម្ពោធច្រករបៀងវប្បធម៌កម្ពុជា-ចិន តួសម្ដែងរបាំរបស់កម្ពុជាកំពុងរាំរបាំប្រពៃណីខ្មែរ
在中柬文化走廊启用仪式上，柬埔寨舞蹈演员表演柬埔寨传统舞蹈 云南国传中心 图



ពិធីសម្ពោធច្រករបៀងវប្បធម៌កម្ពុជា-ចិន មានភាពត្រចះត្រចង់ ដែលវត្ថុតាំងពិព័រណ៍ជាបេតិកភណ្ឌវប្បធម៌អរូបីរបស់ខេត្តយូណាន និងប្រទេសកម្ពុជា ព្រមទាំងការរាំរបាំនៅនឹងកន្លែង បានទាក់ទាញក្រសែភ្នែករបស់ភ្ញៀវទេសចរអន្តរជាតិ

中柬文化走廊启用仪式现场，来自中国云南及柬埔寨的非遗展品和快闪舞蹈吸引了国际旅客的目光 云南国传中心 图 孙勇刚 制图

## ច្រករបៀងវប្បធម៌កសាងស្ពានចំណងមិត្តភាព

搭建友谊之桥

នៅក្នុងខែមិថុនា ឆ្នាំនេះ សកម្មភាពសំឡេងទីតាំងបេតិកភណ្ឌ "ដើរកម្សាន្តនៅយូណាន ទៅទស្សនានៅអង្គរ" នៃប្រទេសចិន(ខេត្តយូណាន)-ព្រះរាជាណាចក្រកម្ពុជា បានបើកនៅទីក្រុងគុនមីង ខេត្តយូណាន។ ពីរខែក្រោយ មិត្តចាស់ និងថ្មីបានមកជួបជុំគ្នានៅខេត្តសៀមរាបនៃប្រទេសកម្ពុជា ដើម្បីពិគ្រោះពិភាក្សាអំពីការពង្រឹងចំណងមិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍនៅពេលអនាគតជាមួយគ្នា។

ឯកឧត្តម ឈាន លាង រដ្ឋលេខាធិការក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងថា "ច្រករបៀងវប្បធម៌កម្ពុជា-ចិន ត្រូវបានបើកសម្ពោធជាផ្លូវការនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ដែលជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ជាប្រវត្តិសាស្ត្រមួយទៀតសម្រាប់ការផ្លាស់ប្តូរប្រជាជន និងប្រជាជនរវាងកម្ពុជា និងចិន"។

ឯកឧត្តម ង៉ូវ សេងកាក់ អភិបាលរងខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា "សកម្មភាពនេះនឹងផ្សព្វផ្សាយដល់ភ្ញៀវទេសចរឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅ និងទូលំទូលាយអំពីវប្បធម៌ដ៏ចំណាស់ និងសម្បូរបែបរបស់កម្ពុជា និងចិន ហើយកិច្ចសហប្រតិបត្តិការនេះនឹងជំរុញកំណើនភ្ញៀវទេសចរ ក៏ដូចជាការរួមចំណែកអភិវឌ្ឍវិស័យទេសចរណ៍ក្នុងខេត្តសៀមរាបផងដែរ"។

ទេសចរណ៍ និងវប្បធម៌បង្កើនទំនាក់ទំនងរវាងប្រជាជន និងប្រជាជន។ ខេត្តយូណាន និងប្រទេសកម្ពុជាមានធនធានបេតិកភណ្ឌពិភពលោកដ៏សម្បូរបែប ដែលបានចាក់គ្រឹះដ៏មានតម្លៃសម្រាប់កិច្ចសហប្រតិបត្តិការវប្បធម៌ និងទេសចរណ៍រវាងភាគីទាំងពីរ។ កាលពីថ្ងៃទី៦ ខែសីហា "ផែនការទេសចរណ៍បេតិកភណ្ឌពិភពលោក" ត្រូវបាន




ចេញផ្សាយ។ លោកស្រី វ៉ាង ជាំងហុង អនុប្រធានមន្ទីរវប្បធម៌ និងទេសចរណ៍ខេត្តយូណាន មានប្រសាសន៍ថា លោកស្រីសង្ឃឹមថា តាមរយៈការសាងសង់ច្រករបៀងវប្បធម៌កម្ពុជា-ចិន ជំរុញកិច្ចសហប្រតិបត្តិការក្នុងវិស័យទេសចរណ៍ និងវប្បធម៌រវាងខេត្តយូណាន និងប្រទេសកម្ពុជា កសាងគំរូថ្មីនៃកិច្ចសហប្រតិបត្តិការទេសចរណ៍ឆ្លងព្រំដែន និងរួមចំណែកសម្រាប់ក្របខណ្ឌកិច្ចសហប្រតិបត្តិការ "ត្បូងពេជ្រ" រវាងប្រទេសកម្ពុជា និងចិន។

## បន្តនិពន្ធរឿងកិច្ចសហប្រតិបត្តិការ

续写合作故事

មកដល់កន្លែងចេញដំណើរសម្រាប់អ្នកដំណើរអន្តរជាតិនៃអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ទើបអាចឃើញបានការតាំងពិព័រណ៍រូបថតដ៏ស្រស់ស្អាតជាមួយប្រធានបទ "ជំនួបបេតិកភណ្ឌពិភពលោក ពួតដៃអរិយធម៌ក្នុងការសិក្សាពីគ្នាទៅវិញទៅមក"។ រូបភាពនៃតំបន់បេតិកភណ្ឌពិភពលោកចំនួន ៦ របស់ខេត្តយូណាន រួមមាន ទេសភាពវប្បធម៌តៃព្រៃ ភ្នំជីងម៉ៃ ក្រុងភូអឺ ព្រៃថ្ម "ទន្លេបីហូរស្របគ្នា" ទីក្រុងបុរាណលីជាំង និងទីតាំងហ្វូស៊ីល ឆឹងជាំង ក្រុងយូស៊ី ដីស្រែកាំជណ្ដើរ ហានី ហុងហឺ ត្រូវបានដាក់តាំងបង្ហាញជាមួយតំបន់បេតិកភណ្ឌពិភពលោកចំនួន ៤ រួមមានប្រាសាទអង្គរវត្ត និងប្រាសាទកោះកេរ្តិ៍ ជាដើមរបស់ប្រទេសកម្ពុជា។ "រូបភាពនេះបានទាក់ទាញអារម្មណ៍យ៉ាងខ្លាំងនាពេលថ្មីៗនេះ។ នារីជនជាតិពូឡាងម្នាក់នៅខេត្តយូណាន បានតុបតែងផ្សិតព្រៃពណ៌ក្រហមនៅលើសក់របស់នាង។ វាមានលក្ខណៈធម្មជាតិ និងពោរពេញដោយភាពច្នៃប្រឌិត"។ "រូបភាពនេះបង្ហាញពីរបាំល្ខោនខោលកម្ពុជា ដែលត្រូវបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ។ ប្រសិនបើអ្នកមានឱកាស លោកអ្នកមុខជានឹងទៅទស្សនាដោយផ្ទាល់"។ ភ្ញៀវបានឈប់នៅមុខរូបភាពទាំងនេះ ដើម្បីស្ដាប់ការណែនាំយ៉ាងលម្អិត។

ការយល់ដឹងពីចិត្តគ្នាយ៉ាងច្បាស់ទាក់ទាញអារម្មណ៍មនុស្ស។ នៅរសៀលថ្ងៃទី៦ ក្រុមរបាំជនជាតិខ្មែរ និងចិនបានសម្ដែងនៅកន្លែងចេញដំណើរសម្រាប់អ្នកដំណើរអន្តរជាតិនៃអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ។ អ្នកសម្ដែងប្រទេសទាំងពីររាំរបាំជាមួយគ្នា មើលទៅដូចមិត្តចាស់ដែលបានស្គាល់គ្នាជាច្រើនឆ្នាំ ហើយនិយាយ




ពិធីសម្ពោធច្រករបៀងវប្បធម៌កម្ពុជា-ចិន មានភាពត្រចះត្រចង់ ដែលវត្ថុតាំងពិព័រណ៍ជាបេតិកភណ្ឌវប្បធម៌អរូបីរបស់ខេត្តយូណាន និងប្រទេសកម្ពុជា ព្រមទាំងការរាំរបាំនៅនឹងកន្លែង បានទាក់ទាញក្រសែភ្នែករបស់ភ្ញៀវទេសចរអន្តរជាតិ

中柬文化走廊启用仪式现场，来自中国云南及柬埔寨的非遗展品和快闪舞蹈吸引了国际旅客的目光 云南国传中心 图 孙勇刚 制图

រឿងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការតាមរយៈការរាំ។ នៅកន្លែងជិតៗ សិល្បៈដេរប៉ាក់ជនជាតិយី ឈូស្យូង និង Stereo Rubbings អក្សរតុងប៉ារបស់លីជាំង កំប៉ុងដាក់ស្លឹកតែធ្វើពីសំណប៉ាហាំងហុងហ៊ី ល្ខោនស្បែកប៉ាវសាន គំនូររូបចម្លាក់ស្បែកទីឈីង សូត្រជនជាតិតៃភូអី និងឧបករណ៍តន្ត្រីក្បាលចៀមនូជាំង ត្រូវបានបង្ហាញជាមួយវត្ថុសិប្បកម្មនៃរបាំល្ខោនខោល ចម្លាក់ឈើ ចម្លាក់ថ្ម ចម្លាក់ឫស្សី និងផលិតផលសូត្ររបស់ប្រទេសកម្ពុជា ហាក់ដូចជាកំពុងសន្ទនាទៅវិញទៅមកដោយស្ងាត់។

លោក CHAN SOPHORN ដែលជាអ្នកទទួលបន្ទុកពាក់ព័ន្ធនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប ប្រទេសកម្ពុជា យល់ឃើញថា "នៅពេលយើងទៅទស្សនាការតាំងពិព័រណ៍ទាំងនេះជាមួយមិត្តរបស់យើងមកពីខេត្តយូណាន ប្រទេសចិន យើងអាចមានអារម្មណ៍ថាមានទំនាក់ទំនងវប្បធម៌រវាងពួកយើង ហើយការផ្លាស់ប្តូរសិល្បៈនឹងជំរុញការយល់ដឹងគ្នាទៅវិញទៅមករវាងវប្បធម៌ផ្សេងៗគ្នា"។ លោកបានបន្តទៀតថា ការសាងសង់ច្រក-របៀងវប្បធម៌កម្ពុជា-ចិន នឹងជួយបង្កើនទំនាក់ទំនង និងមនោសញ្ចេតនារវាងប្រជាជន និងប្រជាជននៃប្រទេសទាំងពីរ និងបង្កើតឱកាសសម្រាប់សិល្បករនៃប្រទេសទាំងពីរ។ នេះក៏ជាក្តីសង្ឃឹមរបស់មនុស្សគ្រប់គ្នា៖ ដើម្បីយកការបើកច្រករបៀងវប្បធម៌កម្ពុជា-ចិនជាឱកាសមួយក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរលើវិស័យផ្សេងៗ និងនាំមកនូវផលប្រយោជន៍កាន់តែច្រើនដល់ប្រជាជននៃប្រទេសទាំងពីរ។